**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១២២ អនក្រ.បក.

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅ នៃលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩៣២ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់
- យោងតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់។

**មាត្រា២ .-**

អនុក្រឹត្យនេះមានគោលបំណងដូចខាងក្រោម៖

- សម្របសម្រួលបេសកកម្មការងាររបស់ឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ជូនរាជរដ្ឋាភិបាល
- ធានាគុណភាពនិងប្រសិទ្ធភាពនៃលទ្ធផលបំពេញការងាររបស់ឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់។

## ជំពូកទី២
## ការរៀបចំលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់

**មាត្រា៣ .-**

លេខាធិការដ្ឋានមានការិយាល័យមួយចំនួនជាសេនាធិការះ

- ការិយាល័យរដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុ
- ការិយាល័យសរុប បណ្ណសារ និងព័ត៌មានវិទ្យា
- ការិយាល័យសាធារណមតិនិងជំនួយការប្រជាជន
- ការិយាល័យនីតិកម្ម
- ការិយាល័យព័ត៌មាននិងទំនាក់ទំនងសាធារណៈ។

**មាត្រា៤ .-**

លេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ដឹកនាំដោយប្រធានមួយរូប អមដោយមន្ត្រីនិងបុគ្គលិកមួយចំនួនក្រោមឱវាទ។

**មាត្រា៥ .-**

គណបក្សនយោបាយនីមួយៗដែលចូលរួមក្នុងឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ត្រូវចាត់តាំងមន្ត្រីរបស់ខ្លួនចំនួន១(មួយ)រូបមកបម្រើការក្នុងលេខាធិការដ្ឋាន អនុលោមតាមមាត្រា១៨នៃព្រះរាជក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់។

មន្ត្រីគណបក្សនយោបាយ ដូចចែងក្នុងវាក្យខ័ណ្ឌ១ខាងលើ បំពេញការងារជាមន្ត្រីទំនាក់ទំនង និងសម្របសម្រួលការងាររបស់ប្រតិភូគណបក្សសាមី ក្នុងក្របខ័ណ្ឌឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ តាមរយៈលេខាធិការដ្ឋាន។

**មាត្រា៦ .-**

លេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់មានមន្ត្រីជំនាញនិងបុគ្គលិកបច្ចេកទេសមួយចំនួនដែលជ្រើសរើសដោយប្រធានលេខាធិការដ្ឋានតាមតម្រូវការ។

មន្ត្រីជំនាញនិងបុគ្គលិកបច្ចេកទេសត្រូវជ្រើសរើសចេញពីមន្ត្រីរាជការ។ ប្រធានលេខាធិការដ្ឋានអាចជ្រើសរើសមន្ត្រីជំនាញបច្ចេកទេសមួយចំនួនផ្សេងទៀតបាន។

**មាត្រា៧ .-**

មន្ត្រីគ្រប់ប្រភេទនិងគ្រប់ថ្នាក់ដូចមានចែងក្នុងមាត្រា៤ មាត្រា៥ និងមាត្រា៦នៃអនុក្រឹត្យនេះ ត្រូវបញ្ចប់ការងាររបស់ខ្លួនក្នុងលេខាធិការដ្ឋាននៅពេលអាណត្តិរបស់ឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ត្រូវបានបញ្ចប់។

## ជំពូកទី៣
## ការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់

**មាត្រា៨ .-**

លេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់មានតួនាទីសម្របសម្រួលការងាររបស់ឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ព្រមទាំងគ្រប់គ្រងកិច្ចការរដ្ឋបាល បុគ្គលិក ឯកសារ ស្ថិតិ ហិរញ្ញវត្ថុ ព័ត៌មានវិទ្យា និងកិច្ចការផ្សេងៗទៀត។

**មាត្រា៩ .-**

លេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ជាសេនាធិការនៃការប្រជុំរបស់ឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ដែលមានភារកិច្ចដូចខាងក្រោម៖

១- ការងារត្រៀមរៀបចំកិច្ចប្រជុំរបស់ឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់រួមមាន៖

- រៀបចំរបៀបវារៈប្រជុំខាងមុខរបស់ឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ពាក់ព័ន្ធនឹងរាល់ឯកសាររបស់ប្រតិភូគណបក្ស ដូចមានចែងក្នុងមាត្រា១០នៃព្រះរាជក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់
- ទទួលយកនូវលទ្ធផលការងារជាលាយលក្ខណ៍អក្សររបស់ប្រតិភូគណបក្ស ដូចមានចែងក្នុងមាត្រា១៦ វាក្យខ័ណ្ឌ១នៃព្រះរាជក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ដើម្បីដាក់ចូលក្នុងរបៀបវារៈប្រជុំខាងមុខរបស់ឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់និងចែកឯកសារទាំងនោះជូនគ្រប់សមាជិកឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ឲ្យបានមុនពេលប្រជុំ
- កំណត់កាលបរិច្ឆេទប្រជុំប្រចាំខែដោយពិគ្រោះនិងឆ្លងយោបល់ជាមួយនឹងប្រធានប្តូរវេន
- រៀបចំចាត់ចែងលិខិតអញ្ជើញភ្ជាប់ជាមួយនឹងឯកសារដែលពាក់ព័ន្ធនឹងរបៀបវារៈប្រជុំ។

២- ការងារក្នុងពេលដំណើរការនៃកិច្ចប្រជុំ

- ទទួលខុសត្រូវលើបញ្ជីវត្តមាននិងពិធីការ
- ធ្វើកំណត់ហេតុនៃកិច្ចប្រជុំនីមួយៗរបស់ឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់។

៣- ការងារក្រោយកិច្ចប្រជុំ

- រៀបចំឯកសារដាក់ជូននាយករដ្ឋមន្ត្រីតាមស្មារតីនៃកិច្ចប្រជុំនីមួយៗរបស់ឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់

- ចងក្រងនិងរក្សាទុកជាឯកសារនូវកំណត់ហេតុនៃរាល់កិច្ចប្រជុំនីមួយៗរបស់ឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់។

**មាត្រា១០ .-**

ក្នុងការអនុវត្តជាក់ស្តែងនូវមាត្រា១០នៃព្រះរាជក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ មន្ត្រីគណបក្សនយោបាយដូចមានចែងក្នុងមាត្រា៥នៃអនុក្រឹត្យនេះត្រូវយកអត្ថបទតាក់តែងនិង/ឬយោបល់ជាលាយលក្ខណ៍អក្សររបស់ប្រតិភូគណបក្សសាមីបញ្ជូនមកលេខាធិការដ្ឋានដើម្បីរៀបចំដាក់បញ្ចូលក្នុងរបៀបវារៈប្រជុំខាងមុខរបស់ឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ យោងតាមការស្នើសុំរបស់ប្រតិភូគណបក្សសាមី។

អនុលោមតាមមាត្រា១៦ វាក្យខណ្ឌ១នៃព្រះរាជក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ មន្ត្រីគណបក្សនយោបាយដូចមានចែងក្នុងមាត្រា៥នៃអនុក្រឹត្យនេះត្រូវសម្រួលនិងរៀបចំឯកសារលើករណីជាក់ស្តែងនីមួយៗដាច់ដោយឡែកពីគ្នារបស់ប្រតិភូគណបក្សសាមីដើម្បីដាក់ជូននាយករដ្ឋមន្ត្រី តាមរយៈលេខាធិការដ្ឋាន។

**មាត្រា១១ .-**

របបឧបត្ថម្ភផ្សេងៗអនុលោមតាមមាត្រា៨នៃព្រះរាជក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ត្រូវធ្វើឡើងផ្អែកលើបេសកកម្មជាក់ស្តែងក្នុងក្របខ័ណ្ឌភារកិច្ចដែលមានចែងក្នុងមាត្រា១០នៃព្រះរាជក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ និងចេញដោយលេខាធិការដ្ឋានតែប៉ុណ្ណោះ។

**មាត្រា១២ .-**

អនុលោមតាមមាត្រា១៩ វាក្យខណ្ឌ២នៃព្រះរាជក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ ការស្វែងរកមូលនិធិពីប្រភពផ្សេងៗត្រូវធ្វើឡើងដោយតម្លាភាពក្នុងក្របខ័ណ្ឌឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់តាមរយៈលេខាធិការដ្ឋានមិនមែនក្នុងក្របខ័ណ្ឌគណបក្សនយោបាយឬប្រតិភូគណបក្សនយោបាយឡើយ។

ថវិកាដែលបានពីមូលនិធិផ្សេងៗត្រូវយកទៅប្រើប្រាស់សម្រាប់លើកស្ទួយនិងពង្រីកវិសាលភាពនៃការបំពេញភារកិច្ចដូចមានចែងក្នុងមាត្រា១០នៃព្រះរាជក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ ដោយមិនរើសអើងគណបក្សនយោបាយតែត្រូវផ្សារភ្ជាប់ជាមួយនឹងការចុះបំពេញបេសកកម្មជាក់ស្តែងរបស់សមាជិកនិងមន្ត្រីលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**មាត្រា១៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា១៤ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ៨កើត ខែភទ្របទ ឆ្នាំចសំរឹទ្ធិស័ក ព.ស.២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៧ខែ កញ្ញា ឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

**កន្លែងទទួល** :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ